NSW GOVERNMENT | Health

*ប័ណ្ណព័ត៌មានអំពីជំងឺឆ្លង*

# ជំងឺកញ្ជ្រឹល៖ ព័ត៌មានសំរាប់អ្នកប៉ះពាល់មេរោគ

*អ្នកប៉ះពាល់មេរោគគឺជាអ្នកដែលបានដកដង្ហើមស្រូបយកខ្យល់រួមគ្នាជាមួយនឹងអ្នកកើតកញ្ជ្រឹល។ អ្នកប៉ះពាល់មេរោគខ្លះដែលគ្មានប្រព័ន្ធការពារទប់ទល់នឹងរោគនេះ អាចកើតកញ្ជ្រឹលបាន លុះត្រាតែអ្នកទាំងនោះទទួលការព្យាបាលបង្ការរោគនេះ។*

**កំណត់សំគាល់សំរាប់អ្នកវិជ្ជាជីវៈថែទាំសុខភាព៖**

- ព័ត៌មាននៅក្នុងប័ណ្ណព័ត៌មាននេះគួរតែបំពេញដោយអ្នកវិជ្ជាជីវៈថែទាំសុខភាពសំរាប់អ្នកជំងឺនីមួយៗ (ថ្ងៃប៉ះពាល់មេរោគ, ប្រាប់ថាតើបានចាក់ថ្នាំ MMR ឬ NHIG ដែរឬទេ និងត្រាការងាររបស់អ្នកវិជ្ជាជីវៈនោះ)។
- គួរផ្តល់ប័ណ្ណព័ត៌មានអំពីជំងឺកញ្ជ្រឹលរបស់ NSW Health ទៅឲ្យអ្នកប៉ះពាល់មេរោគ៖ **www.health.nsw.gov.au/factsheets/infectious/measles.html**

**1.** ថ្ងៃខែឆ្នាំដែលបានប៉ះពាល់អ្នកចម្លងមេរោគ៖ ______________________________

**2.** ឃ្លាំមើលរោគសញ្ញាទាំងឡាយនៃជំងឺកញ្ជ្រឹលរហូតដល់ថ្ងៃទី៖ ____________________

**3.** លោកអ្នកបានទទួលការព្យាបាលដូចតទៅនេះដើម្បីបង្ការជំងឺកញ្ជ្រឹល៖

☐ **ចាក់ថ្នាំបង្ការរោគកញ្ជ្រឹល សាទ្បាទែន ស្អូច (MMR) ក្រោយពីបានប៉ះពាល់នឹងមេរោគកញ្ជ្រឹល**

ថ្នាំបង្ការរោគ MMR អាចធ្វើឲ្យរាងកាយផលិតអង្គបដិបក្ខប្រឆាំងនឹងរោគកញ្ជ្រឹល ហើយអាចការពារទល់នឹងការកើតមានជំងឺនេះ បើបានចាក់ថ្នាំក្នុងរង្វង់ពេល 72 ម៉ោង ក្រោយពីបានប៉ះនឹងវីរុសកញ្ជ្រឹល។ ថ្នាំបង្ការរោគ MMR មិនសមរម្យសំរាប់ជនរាល់រូបទេ។ ស្ត្រីមានផ្ទៃពោះនិងអ្នកមានប្រព័ន្ធការពារទប់ទល់រោគទន់ខ្សោយ មិនគួរចាក់ថ្នាំ MMR ឡើយ។

☐ **ចាក់ថ្នាំ Immunoglobulin ធម្មតាហៅថាថ្នាំ NHIG ក្រោយពីបានប៉ះពាល់នឹងមេរោគកញ្ជ្រឹល**

ថ្នាំ NHIG គឺជាអង្គបដិបក្ខដែលបន្សុទ្ធចេញពីឈាមរបស់អ្នកធ្វើអំណោយឈាម។ ថ្នាំ NHIG អាចផ្តល់ការការពាររយៈពេលខ្លីទល់នឹងកញ្ជ្រឹល បើបានចាក់ថ្នាំនេះក្នុងរង្វង់ពេល 7 ថ្ងៃ ក្រោយពីប៉ះពាល់នឹងមេរោគកញ្ជ្រឹលមក។ ថ្នាំ NHIG មិនផ្តល់ការការពាររយៈពេលយូរឡើយ។ គួរចាក់ថ្នាំ MMR ប៉ុន្តែគួរពន្យារពេល 5 ខែសិន ក្រោយពីបានចាក់ថ្នាំ NHIG ហើយ។

☐ **គ្មានការព្យាបាលទេ ក្រោយពីបានប៉ះពាល់នឹងមេរោគកញ្ជ្រឹលហើយ**

បើការប៉ះពាល់នឹងមេរោគកញ្ជ្រឹលបានកើតឡើងច្រើនជាងពេល 7 ថ្ងៃហើយមកនោះ ថ្នាំ MMR និង NHIG គ្មានប្រសិទ្ធភាពទេ។ លោកអ្នកគួរប្រុងប្រយ័ត្នអំពីការកើតមានរោគសញ្ញានៃជំងឺកញ្ជ្រឹល។

## ព័ត៌មានទូទៅសំរាប់អ្នកប៉ះពាល់មេរោគ

### តើអ្នកប៉ះពាល់មេរោគគឺជាអ្នកណា?

"អ្នកប៉ះពាល់មេរោគ" គឺជាអ្នកដែលបានដកដង្ហើមនូវខ្យល់អាកាសរួមគ្នាជាមួយនឹងជនម្នាក់ទៀតដែលកើតកញ្ជ្រិល (ឧទាហរណ៍៖ ស្ថិតនៅក្នុងបន្ទប់ជាមួយនឹងជនម្នាក់ដែលកើតកញ្ជ្រិល)។ បើជំងឺនេះឆ្លងទៅកាន់អ្នកប៉ះពាល់មេរោគដែលគ្មានប្រព័ន្ធការពារទប់ទល់នឹងរោគនេះ អ្នកប៉ះពាល់នោះអាចកើតមានរោគសញ្ញាកញ្ជ្រិលក្នុងពេល 7 ទៅ 18 ថ្ងៃ ក្រោយពីបានដកដង្ហើមនូវខ្យល់អាកាសរួមគ្នានោះ។

អ្នកប៉ះពាល់មេរោគជាច្រើនមានប្រព័ន្ធការពារទប់ទល់នឹងកញ្ជ្រិល ពីព្រោះតែបានកើតកញ្ជ្រិលកាលពីពេលកន្លងមក ឬ បានចាក់ថ្នាំបង្ការរោគនេះ ហើយនឹងមិនកើតជំងឺនេះទេ។ អ្នកប៉ះពាល់មេរោគផ្សេងទៀតដែលគ្មានប្រព័ន្ធការពារទប់ទល់នឹងរោគនេះ អាចកើតកញ្ជ្រិល ហើយបន្ទាប់មកអាចចម្លងវីរុសនេះទៅអ្នកដទៃ។ ជួនកាលអ្នកដែលគ្មានប្រព័ន្ធការពារទប់ទល់នឹងរោគកញ្ជ្រិល មានលទ្ធភាពបញ្ឈប់ការកើតជំងឺនេះបានតាមរយៈការចាក់ថ្នាំបង្ការរោគ MMR ឬការចាក់ថ្នាំ NHIG ។

### តើអ្នកណាខ្លះដែលអាចមានគ្រោះថ្នាក់កើតជំងឺកញ្ជ្រិល?

កញ្ជ្រិលគឺជាជំងឺធម្មតាមួយនៅមុនឆ្នាំ 1966  ដូច្នេះមនុស្សភាគច្រើនដែលមានកំណើតមុនឆ្នាំនោះមានប្រព័ន្ធការពារទប់ទល់នឹងរោគនេះ។

អ្នកមានគ្រោះថ្នាក់កើតកញ្ជ្រិលមានរួមទាំង៖

- អ្នកមានកំណើតក្នុងអំឡុងឬតាំងពីឆ្នាំ 1966 ដែលមិនធ្លាប់កើតកញ្ជ្រិល និងអ្នកដែលមិនបានចាក់ថ្នាំបង្ការរោគ MMR ចំនួនពីរកំរិត ចាប់ពីអាយុ 12 ខែ។
- អ្នកមានប្រព័ន្ធការពារទប់ទល់រោគទន់ខ្សោយ (ឧទាហរណ៍៖ អ្នកកំពុងព្យាបាលរោគមហារីកតាមវិធីគីមីឬវិទ្យុសកម្ម ឬអ្នកដែលប្រើថ្នាំស្តេរ៉ូអ៊ីដកំរិតខ្ពស់) ទោះជាអ្នកទាំងនោះបានចាក់ថ្នាំបង្ការរោគពេញលេញ ឬធ្លាប់កើតកញ្ជ្រិលរួចហើយក៏ដោយ។

### តើអ្នកប៉ះពាល់មេរោគគួរធ្វើអ្វី?

- ឃ្លាំមើលរោគសញ្ញាកញ្ជ្រិល រហូតដល់ថ្ងៃដែលសរសេរនៅខាងមុខប័ណ្ណព័ត៌មាននេះ។ រោគសញ្ញាដំបូងនៃកញ្ជ្រិលគឺគ្រុនក្តៅ ហៀរសំបោរ ភ្នែកឈឺហៀរទឹកភ្នែក និងក្អក។ កន្ទួលចាប់ផ្តើមលេចចេញឡើងនៅពេលក្រោយមកទៀត។
- ដើម្បីជាវិធានការប្រុងប្រយ័ត្នជាមុននោះ ការរឹតត្បិតការប៉ះពាល់ជាមួយអ្នកមានគ្រោះថ្នាក់កើតកញ្ជ្រិលគឺជាវិធីល្អមួយ រហូតដល់ពេល 18 ថ្ងៃក្រោយពីលោកអ្នកបានប៉ះពាល់មេរោគនេះមក។ បើលោកអ្នកមិនអាចរឹតត្បិតការប៉ះពាល់អ្នកទាំងនេះបានទេ លោកអ្នកគួរព្រមានអ្នកទាំងនោះថា លោកអ្នកអាចចម្លងរោគកញ្ជ្រិល។

### បើលោកអ្នក (ឬកូនលោកអ្នក)កើតមានរោគសញ្ញាកញ្ជ្រិល

- កុំធ្វើដំណើរទៅកាន់កន្លែងសាធារណៈ (ដូចជាកន្លែងធ្វើការ  សាលារៀន  មណ្ឌលថែទាំកុមារ ឬមណ្ឌលលក់ដូរទំនិញជាដើម) ឬប្រើយានជំនិះសាធារណៈឡើយ។
- ទៅជួបវេជ្ជបណ្ឌិតឲ្យបានរហ័សតាមលទ្ធភាពជាពិសេសទៅជួបវេជ្ជបណ្ឌិតរបស់លោកអ្នក ដើម្បីឲ្យគាត់អាចបញ្ជាក់អំពីរោគវិនិច្ឆ័យ។ សូមយកប័ណ្ណព័ត៌មាននេះទៅជាមួយលោកអ្នក។
- ទូរស័ព្ទជំរាបវេជ្ជបណ្ឌិតជាមុន ដើម្បីឲ្យគាត់ប្រុងប្រយ័ត្នអំពីរោគសញ្ញារបស់លោកអ្នក ហើយដើម្បីឲ្យគាត់ធ្វើការរៀបចំពិនិត្យមើលលោកអ្នកដោយសុវត្ថិភាព និងកុំឲ្យជំងឺនេះឆ្លងទៅអ្នកដទៃ។
- ទូរស័ព្ទទៅផ្នែកសុខភាពសាធារណៈ តាមលេខទូរស័ព្ទនៅខាងក្រោមនេះ។

## ដើម្បីទទួលព័ត៌មានបន្ថែម

- ប័ណ្ណព័ត៌មានអំពីជំងឺកញ្ជ្រឹលទូទៅ មាននៅតាមវិបសៃ៖ http://www.health.nsw.gov.au/factsheets/infectious/measles.html

**ព័ត៌មានបន្ថែម – ផ្នែកសុខភាពសាធារណៈ (Public Health) នៅក្នុងរដ្ឋ NSW**



**1300 066 055**

**www.health.nsw.gov.au**